00377256

ឯកសារដើម/Or: D188/4

នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត
អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា


ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 16 / 09 / 2009
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: CA Ly


**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស

ភាគីដាក់ឯកសារ: សហមេធាវីការពារក្ដីរបស់អ្នកស្រី អៀង ធីរិទ្ធ

ដាក់ជូន: សហចៅក្រមស៊ើបអង្កេត

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០៩


ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 26 / 01 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA


**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់

ចំណាត់ថ្នាក់ឯកសារដោយ កសចស


សាធារណៈ
PUBLIC
26/01/2010


ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ការជំទាស់របស់មេធាវីការពារក្ដីទៅនឹងការលើកឡើងអំពីយុត្តាធិការនៅក្នុងសំណើសុំបំពេញកិច្ចស៊ើបសួរលើកទីពីររបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ**

---

ដាក់ដោយ៖

**សហមេធាវីរបស់អ្នកស្រី អៀង ធីរិទ្ធ**

លោក ផាត់ ពៅស៊ាង

កញ្ញា Diana ELLIS QC

**មេធាវីការពារក្ដីរបស់ជនត្រូវចោទផ្សេងទៀត**

**មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី និងដើមបណ្ដឹងរដ្ឋប្បវេណីគ្មានតំណាង**

ផ្ញើជូន៖

**សហចៅក្រមស៊ើបអង្កេត**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Marcel LEMONDE

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក William SMITH

1. នៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៩, ការិយាល័យសហព្រះរាជអាជ្ញា (ក.ស.ព) បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមដែលបានស្នើសុំឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេត (ក.ស.ច.ស)ដើម្បីស៊ើបសួរលើបណ្ដឹងជាក់លាក់មួយចំនួនដែលពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និង ទំនាក់ទំនងផ្លូវភេទដោយបង្ខំ[1]។ នៅថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៩, មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួនបានដាក់សំណើលើកទីពីរស្នើសុំបំពេញកិច្ចស៊ើបសួរដែលពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និង ទំនាក់ទំនងផ្លូវភេទដោយបង្ខំ (សំណើរបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី)[2]។ នៅក្នុងសំណើរបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី បានស្នើសុំឲ្យមានកិច្ចស៊ើបសួរពេញលេញទៅលើអត្ថិភាពនៃបទល្មើសអាពាហ៍ពិពាហ៍ដោយបង្ខំ[3]។

2. មេធាវីការពារក្ដីរបស់អ្នកស្រី អៀង ធីរិទ្ធសូមលើកឡើងថា អ.វ.ត.ក មិនមានយុត្តាធិការទៅលើបទឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ទាំងនេះទេ។ ទោះបីជា អ្នកស្រី ត្រូវបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមក៏ដោយ ក៏ ក.ស.ច.ស ត្រូវតែទទួលយកអង្គហេតុ និងត្រូវស៊ើបសួរទៅលើអង្គហេតុទាំងនេះ។

3. ទោះបីជាសំណើសុំរបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីលើកឡើងយ៉ាងទូលំទូលាយថា អ.វ.ត.ក មានយុត្តាធិការដើម្បីជម្រះក្ដីទៅលើបទឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ទាំងនេះក៏ដោយ ក៏មេធាវីការពារក្ដីសូមលើកឡើងថា នេះមិនមែនជាពេលវេលាត្រឹមត្រូវសំរាប់មេធាវីការពារក្ដីក្នុងការឆ្លើយតបទៅនឹងបញ្ហានេះទេ ហេតុដូច្នេះ មេធាវីការពារក្ដីនឹងមិនឆ្លើយតបចំពោះខ្លឹមសាររបស់សំណើមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីនោះទេ។ មេធាវីការពារក្ដីសូមធ្វើការបញ្ជាក់អះអាងថា ខ្លួនសុំរក្សាសិទ្ធិដើម្បីលើកឡើងអំពីបញ្ហានេះនៅពេលសវនាការបឋម ឬ នៅក្នុងដំណាក់ការណាមួយដែលយល់ថាសមស្រប និងវាចាំបាច់ក្នុងការឆ្លើយតបវិញនោះ។

---

[1] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងដីកាបញ្ជូនរឿងទៅពិនិត្យរបស់សហចៅក្រមស៊ើបអង្កេត និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម, ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៩, ឯកសារលេខ: D146/3 ។

[2] សំណើលើកទីពីរស្នើសុំបំពេញកិច្ចស៊ើបសួរដែលពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងទំនាក់ទំនងផ្លូវភេទដោយបង្ខំ, ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៩, ឯកសារលេខ: D188 ។

[3] កថាខណ្ឌទី ៣១ នៅក្រោមចំណុច (ក) នៃសំណើសុំរបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ។

ឯកសារៈ D188/4

០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស

| ភាគី | កាលបរិច្ឆេទ | ឈ្មោះមេធាវីការពារក្តី | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|---|
| សហមេធាវីរបស់ អ្នកស្រី អៀង ធីរិទ្ធ | ១៦ ខែ កញ្ញា ឆ្នាំ ២០០៩ | លោក ផាត់ ពៅស៊ាង<br>Diana ELLIS, QC | រាជធានីភ្នំពេញ | |